# ព្រះរាជក្រម

នស/រកម/១២០៦/០៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលធ្វើនៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា នាថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៨៧ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារ

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបុត្រ
ប្រធានរដ្ឋសភា
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រ/ល.០៦១២.៥៤០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
ហត្ថលេខា
ម៉ុក ម៉ារ៉េត

លេខ: ... ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ជិនកេន

3/3

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ សាជីណា.កបច

## សេចក្តីថ្លែងហេតុ

## នៃសេចក្តីព្រាងច្បាប់

## ស្តីពីការអនុម័តយល់ព្រមលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

សារធាតុក្លរ៉ូភ្លុយអរក្លូរកាបូន Chlorofluorocarbons (CFCs) ត្រូវបានគេរកឃើញនៅឆ្នាំ ១៩២៨ ក្នុងប្រេងអេប៉ុង សារធាតុធ្វើឱ្យត្រជាក់មាស៊ីនត្រជាក់ សារធាតុរំលាយ សារធាតុពន្លត់អគ្គីភ័យ ។ល។ សារធាតុ CFCs មានជីវិតយូរអង្វែងដែលការភាយរបស់វានឹងឆ្ពោះទៅរកស្រទាប់អូហ្សូន និងធ្វើការបំផ្លាញឧស្ម័នអូហ្សូន។ ការបាត់បង់ស្រទាប់អូហ្សូន ត្រូវបានគេរកឃើញនៅតំបន់អង់តាក់ទិកនាឆ្នាំ១៩៨៥ ដែលតាំងពីពេលនោះ មកការបាត់បង់នេះត្រូវបានគេរកឃើញនៅរយៈកម្ពស់មធ្យម និងរយៈកម្ពស់ខ្ពស់ ។

ក្នុងការគិតគូរអំពីបរិស្ថាន អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិត្រូវបានចាត់តាំងបង្កើតឡើងដើម្បីតាមដាន និងឃ្លាំមើលសភាពការណ៍ប្រែប្រួលនៃបរិស្ថាននៅក្នុងក្របខ័ណ្ឌសកលលោកទាំងមូល និងជាពិសេសដើម្បីលើកឡើងនូវវិធានការចាំបាច់បន្ទាន់មួយចំនួនដែលមនុស្សជាតិត្រូវអនុវត្ត ក្នុងទិសដៅធានានូវនិរន្តរភាពបរិស្ថាន និងរក្សាឱ្យបាននូវគុណភាពនៃភពផែនដីនៅក្នុងការអភិវឌ្ឍ។

ស្រទាប់អូហ្សូននាពេលបច្ចុប្បន្ននេះ មាននិន្នាការផ្លាស់ប្តូរទៅរកការអន្តរាយយ៉ាងធ្ងន់ធ្ងរ ដោយសារតែសកម្មភាពរបស់មនុស្សបង្កឡើង។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ផលវិបាកដ៏ធំបំផុតនៃការបំផ្លាញស្រទាប់អូហ្សូន គឺការប្រែប្រួលមិនធម្មតានៃអាកាសធាតុលើភពផែនដី ដែលជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើសុខភាពមនុស្ស ហើយបង្កឱ្យមានការខូចខាតយ៉ាងដំណំដល់ផលិតភាពរបស់ស្ថានប្រព័ន្ធធម្មជាតិ ស្ថានប្រព័ន្ធសង្គមព្រមទាំងកត្តារូបវន្តផ្សេងៗទៀតដែលមានប្រយោជន៍សម្រាប់មនុស្សជាតិ។ និន្នាការនេះកំពុងត្រូវបានតាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ពីសំណាក់អ្នកឯកទេសវិទ្យាសាស្ត្រផ្នែកបរិស្ថានពិភពលោក ដើម្បីដាក់ចេញនូវវិធានការជាបន្ទាន់នានា ក្នុងទិសដៅកាត់បន្ថយ និងឈានទៅបំបាត់ចោលការប្រើប្រាស់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូននៅក្នុងពេលអនាគត។

ដើម្បីកាត់បន្ថយនូវសារធាតុបំផ្លាញស្រទាប់អូហ្សូន និងអនុវត្តអនុសញ្ញាវីយែនឱ្យមានប្រសិទ្ធភាពអង្គការកម្មវិធីបរិស្ថានពិភពលោក និងប្រតិភូមកពីប្រទេសជាច្រើនបានជួបប្រជុំគ្នានៅទីក្រុងម៉ុងរ៉េអាល់នាឆ្នាំ ១៩៨៧ ដើម្បីអនុម័តលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ជាលទ្ធផលពិធីសារនេះ ត្រូវបានអនុម័តដោយរដ្ឋាភិបាលមកពីប្រទេសជាច្រើន។ ពិធីសារនេះមានការកែសម្រួលជាបន្តបន្ទាប់ ការកែ សម្រួលនេះត្រូវបានពង្រឹងតាមរយៈការកែតម្រូវចំនួនបួនដងនៅក្នុងការអនុម័តនៃពិធីសារទីក្រុងឡុងដុង ១៩៩០ ការធ្វើវិសោធនកម្ម ទីក្រុងកូបេនហាហ្គែន ១៩៩២ ទីក្រុងម៉ុងរ៉េអាល់ ១៩៩៧ និងទីក្រុងប៉េកាំង ១៩៩៩។ ពិធីសារនេះមានគោលបំណងកាត់បន្ថយ និងលុបបំបាត់នូវការភាយចេញនៃសារធាតុដែលបំផ្លាញស្រទាប់អូហ្សូនដែលផលិតដោយមនុស្សជាតិ។

ដោយពិនិត្យឃើញថា កិច្ចការពារស្រទាប់អូហ្សូន ជាកាតព្វកិច្ចរួមដ៏ចាំបាច់របស់ប្រជាពលរដ្ឋទូទាំងពិភពលោក និងដោយឈរលើទស្សនៈថា "ការការពារស្រទាប់អូហ្សូន គឺជាការការពារអាយុជីវិតមនុស្ស និងបរិស្ថាន" ដូចនេះមកដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២នេះ មានប្រទេសចំនួន ១៨៣ បានផ្តល់សច្ចាប័នលើពិធីសារម៉ុងរ៉េអាល់រួចហើយ ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាយើងបានសម្រេចចូលជាសមាជិកនៃពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ កន្លងទៅនេះ ប៉ុន្តែយើងមិនទាន់បានផ្តល់សច្ចាប័នទៅលើវិសោធនកម្មណាមួយក្នុងចំណោមវិសោធនកម្មទាំងបួននៅឡើយទេ។ វិសោធនកម្មទាំងបួននោះមាន ÷

1. The <u>London Amendment</u> to the Montreal Protocol (1990);
2. The <u>Copenhagen Amendment</u> to the Montreal Protocol (1992);
3. The <u>Montreal Amendment</u> to the Montreal Protocol (1997); and
4. The <u>Beijing Amendment</u> to the Montreal Protocol (1999).

ដោយពេលវេលាមានរយៈពេលខ្លី ដូចនេះយើងគួរផ្តល់សច្ចាប័នដល់វិសោធនកម្មទាំងបួននេះកាន់តែឆាប់កាន់តែល្អ។

យោងទៅលើការសិក្សាឯកសារ និងបទពិសោធពីប្រទេសនានានៅក្នុងតំបន់ លើការអនុវត្តពិធីសារនេះដោយប្រៀបធៀបស្ថានភាពជាក់ស្តែងនៅកម្ពុជា ការផ្តល់សច្ចាប័នលើពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន មានសារប្រយោជន៍ដូចខាងក្រោម ÷

១-ក្នុងនាមជាសមាជិកនៃពិធីសារនេះប្រទេសកម្ពុជាពុំត្រូវបង់ថវិកា ឬចំណាយណាមួយឡើយ

២-ក្នុងនាមជាសមាជិកនៃពិធីសារនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមអន្តរជាតិ

ក្នុងការទប់ស្កាត់នូវការវិចរិលនៃស្រទាប់អូហ្សូនដែលបង្កដោយសារធាតុបំផ្លាញស្រទាប់អូហ្សូន ដោយកាត់បន្ថយ និងលុបបំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ដោយទប់ស្កាត់ និងកាត់បន្ថយការនាំចូល ការប្រើប្រាស់ ការកែច្នៃ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន និងឧបករណ៍ដែលប្រើប្រាស់សារធាតុទាំងនេះដែលឧបករណ៍ទាំងនេះភាគច្រើនជាឧបករណ៍ចាស់ៗ ជាធម្មតាប្រទេសនៅក្នុងពិភពលោកយើងកំពុងរកកន្លែងបោះចោល ហើយឧបករណ៍ទាំងនេះនឹងត្រូវប្រើប្រាស់លែងកើតបន្ទាប់ពីឆ្នាំ២០១០ ព្រោះសារធាតុទាំងនេះនឹងត្រូវលុបបំបាត់ទាំងស្រុងពីលើពិភពលោកយើង។

៣.ទទួលផលចំណេញផ្នែកនយោបាយ ÷

-បង្ហាញពីឆន្ទៈរបស់ប្រទេសកម្ពុជា ក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថាន ជាមួយសហគមន៍អន្តរ - ជាតិ

-លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំដែលរៀបចំឡើងសម្រាប់ពិភាក្សា ដោះស្រាយបញ្ហាកាត់បន្ថយសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន។

៤-ទទួលផលចំណេញផ្នែកបរិស្ថាន ÷

-ក្នុងនាមជាសមាជិកនៃពិធីសារនេះ ប្រទេសកម្ពុជាទប់ស្កាត់បាននូវឥទ្ធិពលនៃការកើនកំដៅដែលធ្វើឱ្យខូចខាតបរិស្ថានធម្មជាតិ និងការប៉ះពាល់លើសុខភាពសាធារណៈ ដោយសារការធ្លុះធ្លាយស្រទាប់អូហ្សូន

-ទទួលបាននូវការគាំទ្រលើជំនួយបច្ចេកទេស ក្នុងការបណ្តុះបណ្តាលការផ្តល់នូវបច្ចេកវិទ្យា និងការទទួលព័ត៌មាន និងជំនួយជាថវិកាសម្រាប់អនុវត្តគម្រោងដែលទាក់ទងនឹងការអនុវត្តពិធីសារនេះ ដូចជាការកែច្នៃ ការត្រួតពិនិត្យ ការនាំចូលនូវឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ប្រកបដោយសុវត្ថិភាព។ ដែលបច្ចុប្បន្ននេះ យើងទទួលបានជំនួយផ្នែកពង្រឹងសមត្ថភាព និងការរៀបចំធ្វើកម្មវិធីជាតិដើម្បីកាត់បន្ថយ និងលុបបំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន។

៥-ផលចំណេញផ្នែកសេដ្ឋកិច្ច÷

-ដោយសារកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិត ឬអ្នកនាំចេញឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ដូចនេះ ចូលជាសមាជិកវានឹងមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កម្ពុជាយើងទេ

-អាចចូលរួមក្នុងការអនុវត្តគម្រោងផ្នែក ការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ដែលថវិកាទាំងនេះនឹងទទួលបានពីថវិកាពហុភាគី